雲南日報 报业集团
YUNNAN DAILY PRESS GROUP

# ប្រទេសចិន-ខេត្តយូណាន

១២

កោះសន្តិភាព | លេខ ៥៣ ថ្ងៃ អង្គារ ទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤

澜湄传媒™ Mekong News Network

云南省南亚东南亚区域国际传播中心
Yunnan Int'l Communication Center for South and Southeast Asia

ដោយ ÷ កាសែតយូណានដេលី

# ដំណើរទេសចរណ៍បេតិកភណ្ឌពិភពលោកចេញពីខេត្តយូណាន



## ការពារទ្រព្យសម្បត្តិរួម

ថ្មីៗនេះ ឯកឧត្តម នេត្រ ភក្ត្រា រដ្ឋមន្ត្រីក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានអញ្ជើញមកខេត្តយូណានដើម្បីចូលរួមក្នុងវេទិកាស្តីពីប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិលើកទី៣។ ក្នុងអំឡុងពេលបំពេញទស្សនកិច្ច ឯកឧត្តមបានបង្ហោះសារជាច្រើននៅលើទំព័រហ្វេសប៊ុកផ្លូវការរបស់ខ្លួន ដើម្បីចែករំលែកបទពិសោធន៍នៃព្រឹត្តិការណ៍ និងបទពិសោធន៍ពិសេសរបស់ខ្លួននៅក្នុងមណ្ឌលស្វយ័តជនជាតិតៃ ស៊ីសាំងប៉ាន់ណានៃខេត្តយូណាន ឯកឧត្តមបានប្រាប់អ្នកកាសែតថា «ខេត្តយូណានតែងតែនាំមកនូវការភ្ញាក់ផ្អើល និងអារម្មណ៍ថ្មីដល់អ្នកទស្សនា ទីនេះមានអាកាសធាតុល្អប្រសើរ រុក្ខជាតិសម្បូរបែប អាហារឈ្ងុយឆ្ងាញ់គ្រប់ប្រភេទ ទំនៀមទម្លាប់ជនជាតិចម្រុះពណ៌ និងការធ្វើផែនការរចនាទីក្រុងមានលក្ខណៈវិទ្យាសាស្ត្រ និងសមហេតុផល។ល។»

បន្ទាប់ពីបានទស្សនារោងជាងធ្វើគ្រឿងស្មូនជនជាតិតៃនៅភូមិម៉ាន់ខុនម៉ៃ មណ្ឌលស៊ីសាំងប៉ាន់ណា ឯកឧត្តម នេត្រ ភក្ត្រា បានអញ្ជើញជាងស្មូនក្នុងតំបន់ទៅទស្សនានៅកម្ពុជា ដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងបច្ចេកទេសធ្វើគ្រឿងស្មូន ឯកឧត្តមបានមានប្រសាសន៍ថា «ជំនាញធ្វើគ្រឿងស្មូនតាមប្រពៃណីនៅខេត្តកំពង់ឆ្នាំងរបស់កម្ពុជាគឺល្បីល្បាញណាស់ ផលិតផលមានច្រើនប្រភេទ សិប្បកម្មល្អប្រណិត និងគុណភាពល្អ ហើយត្រូវបានអ្នកប្រើប្រាស់ក្នុងស្រុក និងអតិថិជនបរទេសពេញចិត្តយ៉ាងខ្លាំង»។ ឯកឧត្តមបានថ្លែងថា «រូបរាងការអភិវឌ្ឍទេសចរណ៍ជនបទនៅទីនេះជាមធ្យោបាយដ៏មានប្រសិទ្ធភាពដើម្បីបង្កើនប្រាក់ចំណូល ពួកយើងនឹងនាំយកបទពិសោធន៍អភិវឌ្ឍន៍ទៅប្រទេសកម្ពុជាវិញ ដូចជាការប្រែក្លាយផ្ទះប្រជាជនទៅជាផ្ទះសំណាក់ និងផ្ទះចាស់កែសម្រួលទៅជាហាងកាហ្វេ ហើយចែករំលែកបទពិសោធន៍នៃការបង្កើនប្រាក់ចំណូលតាមរយៈទេសចរណ៍ជនបទ»។

បន្ទាប់ពីបានភ្លក់គុយទាវឆ្លងស្ពានក្តៅៗ ឯកឧត្តម នេត្រ ភក្ត្រា បាននិយាយថា «គុយទាវឆ្លងស្ពានមិនត្រឹមតែមានរសជាតិឈ្ងុយឆ្ងាញ់ប៉ុណ្ណោះទេ ថែមទាំងជានិមិត្តរូបវប្បធម៌របស់យូណានទៀតផង។ មរតករបស់វាមិនត្រឹមតែសរសើរគូស្នេហ៍ដ៏ស្មោះស្ម័គ្រក្នុងសាច់រឿងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឆ្លុះបញ្ចាំងពីក្តីប្រាថ្នា និងការស្វែងរកជីវិតកាន់តែប្រសើរឡើងរបស់ប្រជាជនក្នុងតំបន់។ បើមិត្តខ្មែរទៅទស្សនាខេត្តយូណាន ខ្ញុំណែនាំគាត់ឱ្យសាកល្បងគុយទាវឆ្លងស្ពាន ហើយបើមិត្តចិនមកប្រទេសកម្ពុជាក៏មិនត្រូវរំលងអាម៉ុកប្រពៃណីខ្មែរទេ»។

ឯកឧត្តមបានបញ្ជាក់បន្ថែមទៀតថា «នៅពេលអនាគត យើងទន្ទឹងរង់ចាំប្រព័ន្ធផ្សព្វផ្សាយប្រទេសកម្ពុជា និងខេត្តយូណាន អាចពង្រឹងកិច្ចសហប្រតិបត្តិការកាន់តែស៊ីជម្រៅថែមទៀត និងធ្វើការរួមគ្នា ដើម្បីផ្សព្វផ្សាយទេសចរណ៍ វប្បធម៌ និងការពារតំបន់បេតិកភណ្ឌពិភពលោកនៃប្រទេសទាំងពីរ ហើយទាក់ទាញភ្ញៀវទេសចរឱ្យមកទស្សនាតំបន់បេតិកភណ្ឌពិភពលោកនៅប្រទេសកម្ពុជា និងខេត្តយូណានកាន់តែច្រើនឡើងៗ»។

នៅឯវេទិកាស្តីពីប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិលើកទី៣ ដែលបានប្រារព្ធនៅថ្ងៃទី១០ ខែធ្នូ ពាក្យនិយមប្រើក្នុងការផ្សព្វផ្សាយអន្តរជាតិរបស់ប្រទេសចិនឆ្នាំ២០២៤ ត្រូវបានចេញផ្សាយជាផ្លូវការ ហើយ "ការធ្វើដំណើរប្រទេសចិន" និង "បេតិកភណ្ឌពិភពលោក" ត្រូវបានជ្រើសរើសយកមកប្រើប្រាស់។ ចាប់តាំងពីឆ្នាំនេះមក ប្រទេសចិនបានបន្តអនុវត្តយ៉ាងស៊ីជម្រៅនូវគោលនយោបាយលើកលែងទិដ្ឋាការ ហើយ "ទេសចរណ៍ចិន (China Travel)" បានក្លាយទៅជាម៉ូតទាន់សម័យ។ ខេត្តយូណាននៃប្រទេសចិនមានតំបន់បេតិកភណ្ឌវប្បធម៌ និងធម្មជាតិពិភពលោកចំនួនប្រាំមួយ ដែលទាក់ទាញភ្ញៀវទេសចរបរទេសមួយចំនួនធំដើម្បីស្វែងយល់ពីបេតិកភណ្ឌវប្បធម៌ដ៏សម្បូរបែប និងទេសភាពធម្មជាតិរបស់វា។



## ចាប់ផ្តើមដំណើរដ៏អស្ចារ្យ

«មិត្តភក្តិមកពីជុំវិញពិភពលោក ពេលធ្វើដំណើរទៅកាន់តំបន់បេតិកភណ្ឌពិភពលោករបស់ខេត្តយូណាន ដីស្រែរាងកាំជណ្តើរហានី ហុងហឺ គឺជាកន្លែងទស្សនាដែលមិនគួររំលង»។ មិនយូរប៉ុន្មាន លោក **Pavel Georgiev Galabov** មកពីប្រទេសប៊ុលហ្គារី ដែលមានល្បីឈ្មោះតាមបណ្តាញអ៊ីនធើណែត បានទស្សនានៅភូមិអាជីខឺ ដែលស្ថិតនៅក្នុងតំបន់បេតិកភណ្ឌដីស្រែរាងកាំជណ្តើរហានី ហុងហឺ ហើយបានណែនាំទេសភាពស្រស់ស្អាតដ៏អស្ចារ្យដល់មិត្តភក្តិមកពីជុំវិញពិភពលោក។

"ផ្ទះផ្សិត" នៅក្នុងភូមិអាជីខឺត្រូវបានរាយប៉ាយនៅក្នុងចំណោមភ្នំ និងទឹកពណ៌បៃតង ទឹកថ្លាហូរឆ្លងកាត់ភូមិ ហើយដីស្រែរាងកាំជណ្តើរឆ្លុះបញ្ចាំងពីពណ៌នៃមេឃដូចកញ្ចក់។ លោកបានកោតសរសើរថា «ភូមិ ដីស្រែរាងកាំជណ្តើរ ព្រៃឈើ និងប្រព័ន្ធទឹកត្រូវបានបញ្ចូលជាមួយគ្នា មើលទៅដូចគំនូរព្រេងដ៏ស្អាតប្រណិតមួយ»។

អ្វីដែលធ្វើឱ្យលោក **Pavel Georgiev Galabov** ភ្ញាក់ផ្អើលនោះគឺវប្បធម៌ប្រជាប្រិយក្នុងតំបន់។ ក្នុងអំឡុងពេលទស្សនានៅភូមិអាជីខឺ លោកបានស្លៀកសម្លៀកបំពាក់ជនជាតិក្នុងតំបន់ និងរាំជាមួយអ្នកភូមិក្នុងតំបន់។ គាត់បានចែករំលែកដោយក្តីរំភើបថា «ខ្ញុំបានស្តាប់បទចម្រៀងហានីប្រពៃណីបុរាណដែលត្រូវបានអ្នកស្រុកចាត់ទុកថាជា "សព្វវចនាធិប្បាយ" ហើយបានឃើញ "ឧបករណ៍ភ្លេងបួនខ្សែ" ដែលមានអាយុកាលមួយរយឆ្នាំមកហើយ ដែលឧបករណ៍នេះចាស់ជាងជីតារបស់ខ្ញុំទៅទៀត ពិតជាអស្ចារ្យមែនទែន»!

បន្ទាប់ពីបានសិក្សាអំពីប្រព័ន្ធអេកូឡូស៊ី "ការបង្កើតដោយធាតុទាំងបួនរួមគ្នា" ដែលត្រូវបានថែរក្សាយ៉ាងពេញលេញនៃព្រៃឈើ ភូមិ (ភូមិ និងអ្នកភូមិ) ដីស្រែរាងកាំជណ្តើរ និងទឹក (ប្រភពទឹក និងប្រព័ន្ធទឹក) ហើយស្វែងយល់ពីកន្លែងតាំងទីលំនៅបែបប្រពៃណីជនជាតិហានី និងវប្បធម៌ហានីដ៏យូរជាពិសេស ភ្នែករបស់លោកពោរពេញទៅដោយការគោរព ហើយបានប្រាប់អ្នកកាសែតថា «វាសម្រេចបាននូវវដ្តមួយប្រកបដោយគុណធម៌រវាងការការពារ និងការអភិវឌ្ឍតំបន់បេតិកភណ្ឌពិភពលោក ចិញ្ចឹមជីវិតរបស់ប្រជាជនហានីក្នុងតំបន់ ហើយក៏បង្ហាញដល់ពិភពលោកនូវការរុករកប្រកបដោយជោគជ័យរបស់ប្រទេសចិននៅលើផ្លូវទៅកាន់ការការពារតំបន់បេតិកភណ្ឌពិភពលោកផងដែរ»។

### ព័ត៌មានបន្ថែម

ខេត្តយូណានមានតំបន់បេតិកភណ្ឌពិភពលោកចំនួន ៦ ដែលជាប់ចំណាត់ថ្នាក់លេខ២ ក្នុងប្រទេសចិន រួមមានទីក្រុងបុរាណលីជាំង តំបន់អភិរក្សទន្លេបីហូរស្របគ្នា ព្រៃថ្ម ទីតាំងហ្វូស៊ីលឆឹងជាំង ទេសភាពវប្បធម៌ដីស្រែរាងកាំជណ្តើរហានី ហុងហឺ និងទេសភាពវប្បធម៌ព្រៃតែបុរាណលើភ្នំជីងម៉ៃ ក្រុងភូអឺ៕ (រូបភាពដោយកាសែតយូណានដេលី)

ដោយ ÷ លី សុវណ្ណ និង ជុំ ហៃ

## "អ្នកអភិរក្សព្រៃពណ៌ឥន្ទធនូ" ក្នុងជ្រលងភ្នំ



បន្ទាប់ពីមានភ្លៀងធ្លាក់ខ្លាំង ជ្រលងទន្លេទូឡុងជាំងជុំវិញដោយអ័ព្ទ និងទឹកភ្លៀង។ លោកស្រី លី យូហួ ដែលយកក្រណាត់ចម្រុះពណ៌មួយជាប់នឹងខ្លួន និងមិត្តរួមការងាររបស់នាងបានចូលទៅក្នុងជ្រលងភ្នំ និងព្រៃជ្រៅ ដើម្បីចាប់ផ្តើមការងារដើរល្បាតភ្នំ និងព្រៃ។

ឃុំទូឡុងជាំងមានទីតាំងនៅក្នុងស្រុកស្វយ័តជនជាតិទូឡុង និងជនជាតិនូ កុងសាន មណ្ឌលស្វយ័តជនជាតិលីស៊ូ នូជាំង ខេត្តយូណាន។ ក្នុងឆ្នាំ២០១៦ លោកស្រី លី យូហួ ត្រូវបានជ្រើសរើសជាអ្នកអភិរក្សព្រៃអេកូឡូស៊ីនៅក្នុងភូមិទីជឹងតាង ឃុំទូឡុងជាំង ស្រុកកុងសាន។ ក្នុងរយៈពេល ៨ ឆ្នាំកន្លងមកនេះ លោកស្រី លី យូហួ តែងតែបានខិតខំពង្រឹងសមត្ថភាព និងសិក្សាពីចំណេះដឹងជំនាញ ហើយធ្វើដំណើរទៅមកនៅលើភ្នំ និងក្នុងព្រៃ។ ដោយសារតែលោកស្រីចូលចិត្តយកក្រណាត់ចម្រុះពណ៌មួយជាប់នឹងខ្លួន ដូច្នេះ គាត់ត្រូវបានអ្នកភូមិហៅថា "អ្នកអភិរក្សព្រៃពណ៌ឥន្ទធនូ"។

នៅពេលនិយាយអំពីការប្រែប្រួលនៃបរិស្ថានអេកូឡូស៊ីនៅស្រុកកំណើត លោកស្រីពិតជាមានមោទនភាពយ៉ាងខ្លាំង។ គាត់បានប្រាប់អ្នកកាសែតថា «ឥឡូវនេះ ព្រៃឈើកាន់តែក្រាស់ទៅៗ ទន្លេមានទឹកកាន់តែថ្លាឆ្វង់ ហើយមានសត្វព្រៃកាន់តែច្រើនឡើងៗពីមួយឆ្នាំទៅមួយឆ្នាំ ជួនកាល ខ្លាឃ្មុំផេនដា និងសត្វស្វាក៏រត់ចូលភូមិដែរ»!

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ឧស្សាហកម្មទេសចរណ៍នៅក្នុងឃុំទូឡុងកំពុងបានរីកចម្រើនយ៉ាងឆាប់រហ័ស ហើយក្រណាត់ទូឡុងដែលត្បាញដោយដៃនោះ កំពុងមានប្រជាប្រិយភាពយ៉ាងខ្លាំងក្នុងចំណោមភ្ញៀវទេសចរ។ លោកស្រី លី យូហួ បានសហការជាមួយស្ត្រីតម្បាញមកពីភូមិផ្សេងទៀត ដើម្បីបង្កើតជាសហករណ៍ក្រណាត់ទូឡុង ដើម្បីសហការជាមួយនឹងក្រុមហ៊ុនផលិតសម្លៀកបំពាក់ និងសហគ្រាសវប្បធម៌ក្រុងសៀងហៃ ហើយរួមបញ្ចូលគ្នានូវគំនិតផ្គូផ្គងពណ៌ទំនើបជាមួយនឹងសិប្បកម្មតម្បាញបុរាណរបស់ជនជាតិទូឡុង មកត្បាញជាផលិតផលក្រណាត់ទូឡុងគ្រប់មុខដូចជាកន្សែងបង់ក កូនខ្នើយ កាបូបស្ពាយ និងកន្សែងធំៗជាដើម ដែលបានស្វែងរកឃើញផ្លូវមួយខ្សែសម្រាប់ស្ត្រីជនជាតិទូឡុងបង្កើតអាជីវកម្ម និងបង្កើនប្រាក់ចំណូលរបស់ខ្លួន "នៅមុខទ្វារផ្ទះ"៕

អ្នកនិពន្ធភាសាចិន៖ RAN XIULAN អ្នកនិពន្ធភាសាខ្មែរ៖ LI ZHA SHEN YAN រចនារូបភាព៖ SUN YONGGANG